ការិយាល័យកណ្តាល

អេស៊ីលីដា
ACLEDA BANK

# សេចក្តីជូនដំណឹង

## ស្តីពី

## វឌ្ឍនភាពវិនិយោគរបស់អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ លើមូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅផ្សារមូលបត្រកម្ពុជា ("ផ.ម.ក.")

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** (“ធនាគារ អេស៊ីលីដា”) ជាធនាគារពាណិជ្ជទីមួយក្នុងប្រទេសកម្ពុជា ដែលបានបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈនៅ ផ.ម.ក. មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន និងវិនិយោគិនទាំងអស់ មេត្តាជ្រាបថា ដោយអនុលោមតាមសេចក្តីជូនដំណឹង ស្តីពីផែនការវិនិយោគរបស់អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ លើមូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ធនាគារ អេស៊ីលីដា ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២២ និងរបាយការណ៍ ស្តីពីការទិញភាគហ៊ុន គិតត្រឹមដំណាច់ខែកក្កដា ឆ្នាំ២០២២ អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ បានទិញមូលបត្រកម្មសិទ្ធិរបស់ធនាគារ អេស៊ីលីដា នៅ ផ.ម.ក. **សរុបចំនួន ៣,៣២៩ លាន ភាគហ៊ុន**។

ទន្ទឹមនឹងនេះ អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ **នៅតែបន្តទិញភាគហ៊ុន** របស់ធនាគារ អេស៊ីលីដា ស្របតាមផែនការរបស់ខ្លួន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន និងវិនិយោគិនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃចន្ទ ៤កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១ ខែសីហា ឆ្នាំ២០២២

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**

ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#61, Preah Monivong Blvd., Sangkat Srah Chork, Khan Daun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP